ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 01 / 2016
ម៉ោង (Time/Heure) : 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំដកសាក្សីមួយរូបចេញពីបញ្ជីសាក្សីសម្រាប់សវនាការនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E346/2/1)

១. អង្គជំនុំជម្រះបានទទួលសំណើសុំមួយដែលបានដាក់នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ ដែលនៅក្នុងនោះ មេធាវីការពារក្តី នួន ជា សុំដកសាក្សីដែលមានរហស្សនាម 2-TCW-989 ចេញពីបញ្ជីសាក្សីដែលត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ (ឯកសារ E346/2/1)។ កាលពីខែ មេសា ឆ្នាំ ២០១៥ ជាការឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះបានសម្រេចថា នឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-989 ហើយបានបញ្ជាក់ថាសម្អាងហេតុនៃសេចក្តីសម្រេចនោះនឹងចេញនៅពេលក្រោយ (ឯកសារ E346/2)។ នាពេលនេះ មេធាវីការពារក្តីបានលើកឡើងថា ក្នុងអំឡុងដែលខ្លួនសួរដេញដោលសាក្សី 2-TCW-989 នៅក្នុងសវនាការលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនាពេលកន្លងមក ខ្លួនបានទទួលព័ត៌មានគ្រប់គ្រាន់ពីសក្ខីកម្មសាក្សីរូបនេះរួច

ហើយពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះអតីតទាហាន និង មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ។ មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ភាគីទាំងអស់មានឱកាសក្នុងការតាំងសំណួរដល់សាក្សីរូបនេះនៅក្នុងសវនាការលើបណ្តឹងសាទុក្ខបាន ហេតុនេះ ការស្តាប់សក្ខីកម្មសាក្សី 2-TCW-989 នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ គឺច្រំដែល និង មិនមានប្រយោជន៍ទេ (ឯកសារ E346/2/1 កថាខណ្ឌ ៩)។ សារណាតបផ្ទាល់មាត់ទៅនឹងសំណើសុំខាងលើត្រូវបានធ្វើឡើងថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦។

២. សហព្រះរាជអាជ្ញាលើកឡើងថា សាក្សី 2-TCW-989 គឺជាសាក្សីរបស់អង្គជំនុំជម្រះ ហើយហេតុនេះ គាត់មិនមែនជាសាក្សីរបស់ នួន ជា ដែលអាចដកចេញទេ។ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា មានឯកសារជាច្រើនមាននៅក្នុងសំណុំរឿង ០០២/០២ នាពេលបច្ចុប្បន្ននេះ មិនត្រូវបានផ្តល់ទៅឱ្យសាក្សីរូបនេះក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខឡើយ រួមទាំងចម្លើយដែលគាត់បានផ្តល់ទៅឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ។ សហ-ព្រះរាជអាជ្ញាអះអាងថា សក្ខីកម្មសាក្សីរូបនេះមិនទាន់អាចជឿជាក់បានទេ ហើយថា មានភ័ស្តុតាងជាច្រើនដែលមានភាពផ្ទុយគ្នាទៅនឹងការលើកឡើងរបស់សាក្សីនេះ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាទុកឱ្យអង្គជំនុំជម្រះជាអ្នកសម្រេចថាតើគួរស្តាប់សក្ខី-កម្មសាក្សីរូបនេះ ឬ យ៉ាងណានោះ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ១-៣ (ភាសាអង់គ្លេស, សាធារណៈ))។

៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏លើកឡើងផងដែរថា សាក្សី 2-TCW-989 គឺជាសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមែនជាសាក្សីដែលត្រូវដកចេញពីបញ្ជីសាក្សីរបស់ នួន ជា ទេ។ ពួកគេលើកឡើងថា អង្គជំនុំជម្រះជាអ្នកសម្រេចថាតើ ការស្តាប់សក្ខីកម្មសាក្សីរូបនេះ មានប្រយោជន៍ក្នុងការស្វែងរកការពិត ឬ យ៉ាងណា (ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ៤ (ភាសាបារាំង, សាធារណៈ))។

៤. មេធាវីការពារក្តី ខៀវ សំផន កត់សម្គាល់ថា សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានចាត់ទុកថា ជាការសំខាន់ដែលត្រូវស្តាប់សក្ខីកម្មសាក្សី 2-TCW-989 លើបណ្តឹងសាទុក្ខទេ។ មេធាវីការពារក្តីលើកឡើងថា វាមិនទាន់ដល់ពេលត្រូវធ្វើសេចក្តីសន្និដ្ឋានទៅលើភាពជឿជាក់បានរបស់សាក្សីរូបនេះ ដូចដែលសហព្រះរាជអាជ្ញា

បានធ្វើរួចនោះទេ។ ទោះបីជាមេធាវីការពារក្ដីទុកឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហានេះក៏ដោយ តែមេធាវីការពារក្ដីកត់សម្គាល់ថា វាហាក់ដូចជាការខ្ជះខ្ជាយពេលវេលាក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ ហើយវានឹងមានប្រយោជន៍ជាង ប្រសិនបើអង្គជំនុំជម្រះសាលា-ដំបូងស្ដាប់សក្ខីកម្មសាក្សីផ្សេងទៀតដែលពិតជាស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ពិតប្រាកដ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ៥-៦ (ភាសាបារាំង, សាធារណៈ))។

៥. មេធាវីការពារក្ដី នួន ជា បានឆ្លើយតបវិញថា ការស្ដាប់សក្ខីកម្មសាក្សី 2-TCW-989 គឺជាការចំណាយពេលឥតប្រយោជន៍។ មេធាវីការពារក្ដីលើកឡើងថា សាក្សីរូបនេះគួរឲ្យជឿជាក់បានជាខ្លាំង។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីទទួលស្គាល់ថា សាក្សី 2-TCW-989 គឺជាសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះបានសំអាងលើកំណត់ហេតុស្ដាប់ចម្លើយសាក្សីរាប់រយដោយមិនបានស្ដាប់សក្ខីកម្មសាក្សី ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងក៏អាចសំអាងលើប្រតិចារឹកនៃសវនាការលើបណ្ដឹងសាទុក្ខចំពោះសក្ខីកម្មរបស់សាក្សី 2-TCW-989 ជំនួសឲ្យការស្ដាប់សក្ខី-កម្មគាត់ដោយផ្ទាល់បានដែរ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ៥-៨ (ភាសាអង់គ្លេស, សាធារណៈ))។

៦. ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា សំណើសុំរបស់មេធាវីការពារក្ដី នួន ជា ពុំបានដាក់ទាន់ពេលវេលាទេ។ អង្គជំនុំជម្រះតុលាការកំពូលបានស្ដាប់សក្ខីកម្មសាក្សី 2-TCW-989 នេះនៅខែ កក្កដា ឆ្នាំ ២០១៥។ ហេតុនេះ សំណើសុំបានធ្វើឡើងប្រាំមួយខែក្រោយពេលស្ដាប់សក្ខីកម្មសាក្សីរូបនេះលើបណ្ដឹងសាទុក្ខ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានទទួលយកប្រតិចារឹកក្នុងសំណុំរឿង ០០២/០២ នៅខែ កញ្ញា ឆ្នាំ ២០១៥ (ឯកសារ E356/2) ដែលបន្ទាប់ពីពេលនោះមក មេធាវីការពារក្ដី នួន ជា មិនបានជូនដំណឹងដល់អង្គជំនុំជម្រះពីការព្រួយបារម្ភរបស់ខ្លួនចំពោះការស្ដាប់សក្ខីកម្មសាក្សីរូបនេះនោះទេ រហូតដល់ខែ មករា ឆ្នាំ ២០១៦ ទើបបានលើកឡើងដូច្នេះ។ ការធ្វើបែបនេះធ្វើឲ្យមានការលំបាកជាច្រើនដល់ភាគី និង អង្គជំនុំជម្រះសាលាដំបូង ដោយសារសាក្សីរូបនេះនឹងត្រូវមកផ្ដល់សក្ខីកម្មក្នុងរយៈពេលពីរបីសប្ដាហ៍ខាងមុខ ដីកាកោះហៅសាក្សីត្រូវបានចេញរួចហើយ ហើយការរៀបចំត្រៀមសម្រាប់សវនាការជាមួយអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ក៏ត្រូវបានធ្វើរួចរាល់ហើយដែរ។

៧. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា សាក្សីរូបនេះត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មលើអង្គហេតុស្តីពីការប្រព្រឹត្តិចំពោះអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលពិតជាផ្នែកមួយនៃសំណុំរឿង ០០២/០២ ទាក់ទិនទៅនឹងសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់ (ឯកសារ E315 កថាខណ្ឌ ១៤, ឯកសារ E346/3 កថាខណ្ឌ ៣៣ ដល់ ៣៤)។ ក្រៅពីនេះទៀត ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលមិនបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាសាកសួរសាក្សីរូបនេះចំពោះចម្លើយដែលគាត់បានផ្តល់ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាទេ (ឯកសារ E305/13.23.405 និង E3/9118) ដោយសារសហព្រះរាជអាជ្ញាមិនបានផ្តល់លេខយោងទំព័រជាក់លាក់ (ឯកសារ F26/12 ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ៣)។ អាស្រ័យហេតុនេះ សក្ខីកម្មរបស់សាក្សី 2-TCW-989 នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អាចផ្តោតលើអង្គហេតុនានាដែលមិនទាន់បានសួរដេញដោលនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ។ លើសពីនេះ ទោះបីភាគីមានឱកាសសួរដេញដោលសាក្សីរូបនេះក្នុងបរិបទនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំទាន់មានឱកាសបែបនោះដែរ។ ក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មសាក្សី 2-TCW-989 មានប្រយោជន៍ក្នុងការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២/០២ នេះ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំរបស់មេធាវីការពារក្តី នួន ជា។

៨. ឯកសារនេះគឺជាការឆ្លើយតបផ្លូវការទៅនឹងឯកសារ E346/2/1។